ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៨៥៨.....សហវ.ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការពិន័យជាប្រាក់ចំពោះបុគ្គល ឬនីតិបុគ្គល ដែលប្រព្រឹត្តអំពើល្មើសនឹងវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

Scanned with CamScanner

- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ២៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការកែសម្រួលមាត្រា៨នៃអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីវិធានការសុខាភិបាល ដើម្បីទប់ស្កាត់និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ការពិន័យជាប្រាក់ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ត្រូវបានអនុវត្តចំពោះបុគ្គល ឬនីតិបុគ្គលដែលប្រព្រឹត្តអំពើល្មើសនឹងវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និងដើម្បីទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល។

**ប្រការ២.-**

ប្រភេទបទល្មើស និងកម្រិតទឹកប្រាក់ពិន័យទៅតាមប្រភេទបទល្មើសនីមួយៗ ត្រូវបានរៀបចំជាបញ្ជីពិន័យជាប្រាក់ ដូចខាងក្រោម ÷

| ល.រ | បរិយាយ | កម្រិតទឹកប្រាក់ពិន័យអន្តរការណ៍ដោយក្រសួងសុខាភិបាល | | កម្រិតទឹកប្រាក់ផ្តន្ទាទោស ដោយសាលាជម្រះក្តី (រៀល) |
|---|---|---|---|---|
| | | ទឹកប្រាក់ (រៀល) | រយៈពេលបង់ប្រាក់ | |
| I- ប្រភេទបទល្មើសចែងក្នុងអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត | | | | |
| ១ | បុគ្គលដែលមិនអនុវត្តនូវកាតព្វកិច្ចពាក់ម៉ាស់ ដូចមានចែងក្នុងមាត្រា៥ ឬកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាពបុគ្គល ដូចមានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យ (មាត្រា១៩) | ពី ២០០.០០០ ដល់ ១.០០០.០០០ | ៣០ថ្ងៃ | |



Scanned with CamScanner

| | | | | |
|---|---|---|---|---|
| ២ | អ្នកទទួលខុសត្រូវក្នុងការរៀបចំការជួបជុំមនុស្ស ឬសកម្មភាពសង្គមដទៃទៀត ដែលមិនគោរពវិធានការរក្សាគម្លាតសុវត្ថិភាពសង្គម ដូចមានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យ (មាត្រា១៩) | ពី ១.០០០.០០០ ដល់ ៥.០០០.០០០ | ៣០ថ្ងៃ | |
| ៣ | សហគ្រាស ឬគ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម ដែលមិនបានអនុវត្តកាតព្វកិច្ចទាក់ទងនឹងការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ដូចមានចែងក្នុងមាត្រា៦ និងមាត្រា៧ នៃអនុក្រឹត្យ (មាត្រា២០) | ពី ២.០០០.០០០ ដល់ ១០.០០០.០០០ | ៣០ថ្ងៃ | |
| ៤ | បុគ្គលដែលមិនសហការជាមួយមន្ត្រីសុខាភិបាល ដើម្បីយកវត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩ ដូចមានចែងក្នុងមាត្រា១០ នៃអនុក្រឹត្យ (មាត្រា២១) | ពី ១.០០០.០០០ ដល់ ៥.០០០.០០០ | ៣០ថ្ងៃ | |
| | ក្នុងករណីដែលអំពើល្មើសខាងលើ ត្រូវបានប្រព្រឹត្តម្តងទៀត (មាត្រា២៧) | ពី ២.០០០.០០០ ដល់ ១០.០០០.០០០ | ៣០ថ្ងៃ | |
| ៥ | បុគ្គលដែលគេចវេះពីការធ្វើចត្តាឡីស័ក ឬគេចចេញពីទីកន្លែងធ្វើចត្តាឡីស័ក ក្នុងអំឡុងពេលធ្វើចត្តាឡីស័ក តែមិនបានបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ (មាត្រា២២) | ពី ១.០០០.០០០ ដល់ ៥.០០០.០០០ | ៣០ថ្ងៃ | |
| | ក្នុងករណីដែលអំពើល្មើសខាងលើ ត្រូវបានប្រព្រឹត្តម្តងទៀត (មាត្រា២៧) | ពី ២.០០០.០០០ ដល់ ១០.០០០.០០០ | ៣០ថ្ងៃ | |
| | បុគ្គលដែលធ្វើចត្តាឡីស័ក ដែលមិនអនុវត្តនូវកាតព្វកិច្ចដូចមានចែងក្នុងចំណុចទី១ និងទី២ នៃមាត្រា១៣ នៃអនុក្រឹត្យ (មាត្រា២២) | ពី ៥០០.០០០ ដល់ ២.០០០.០០០ | ៣០ថ្ងៃ | |
| | ក្នុងករណីដែលអំពើល្មើសខាងលើ ត្រូវបានប្រព្រឹត្តម្តងទៀត (មាត្រា២៧) | ពី ១.០០០.០០០ ដល់ ៤.០០០.០០០ | ៣០ថ្ងៃ | |
| ៦ | អ្នកផ្តើមគំនិត ដឹកនាំ ណែនាំ ញុះញង់ បញ្ចុះបញ្ចូល ឬជួយសម្រួលដោយចេតនា ដល់បុគ្គលដែលត្រូវធ្វើចត្តាឡីស័កឱ្យគេចចេញពីការត្រួតពិនិត្យរបស់មន្ត្រីចត្តាឡីស័ក ឬគេចវេះពីការធ្វើចត្តាឡីស័ក ឬគេចចេញពីកន្លែងធ្វើចត្តាឡីស័ក តែមិនបានបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ (មាត្រា២៣) | ពី ១០.០០០.០០០ ដល់ ៥០.០០០.០០០ | ៣០ថ្ងៃ | |
| | ក្នុងករណីដែលអំពើល្មើសខាងលើ ត្រូវបានប្រព្រឹត្តម្តងទៀត (មាត្រា២៧) | ពី ២០.០០០.០០០ ដល់ ១០០.០០០.០០០ | ៣០ថ្ងៃ | |
| ៧ | អ្នកជំងឺកូវីដ-១៩ ដែលត្រូវបានដាក់ឱ្យនៅដាច់ដោយឡែកដើម្បីទទួលការព្យាបាល ដែលមិនអនុវត្តនូវកាតព្វកិច្ច ដូចមានចែងក្នុងចំណុចទី១ និងទី២ នៃកថាខណ្ឌទី២ នៃមាត្រា១៤ នៃអនុក្រឹត្យ (មាត្រា២៤) | ពី ២.០០០.០០០ ដល់ ១០.០០០.០០០ | ៣០ថ្ងៃ | |
| | ក្នុងករណីដែលអំពើល្មើសខាងលើ ត្រូវបានប្រព្រឹត្តម្តងទៀត (មាត្រា២៧) | ពី ៤.០០០.០០០ ដល់ ២០.០០០.០០០ | ៣០ថ្ងៃ | |
| ៨ | បុគ្គលដែលបានចាត់ចែងសាកសពដែលមានផ្ទុកមេរោគកូវីដ-១៩ ល្មើសនឹងមាត្រា១៥ នៃអនុក្រឹត្យ (មាត្រា២៥) | ពី ៥.០០០.០០០ ដល់ ២០.០០០.០០០ | ៣០ថ្ងៃ | |
| | ក្នុងករណីដែលអំពើល្មើសខាងលើ ត្រូវបានប្រព្រឹត្តម្តងទៀត (មាត្រា២៧) | ពី ១០.០០០.០០០ ដល់ ៤០.០០០.០០០ | ៣០ថ្ងៃ | |



Scanned with CamScanner

| | | | | |
|---|---|---|---|---|
| ៩ | គ្រឹះស្ថានសុខាភិបាលឯកជនទាំងអស់ ដែលមិនបានធ្វើការជូនដំណឹងបន្ទាន់ទៅក្រសួងសុខាភិបាល ក្នុងករណីពិនិត្យឃើញថាអ្នកជំងឺដែលកំពុងទទួលសេវាព្យាបាលនៅក្នុងគ្រឹះស្ថានរបស់ខ្លួនមានតម្រុយបញ្ជាក់ថាជាអ្នកជំងឺដែលគេចវេះពីការធ្វើចត្តាឡីស័ក ឬកំពុងគេចចេញពីកន្លែងធ្វើចត្តាឡីស័ក (មាត្រា២៦) | ពី ១០.០០០.០០០ ដល់ ៥០.០០០.០០០ | ៣០ថ្ងៃ | |
| | ក្នុងករណីដែលអំពើល្មើសខាងលើ ត្រូវបានប្រព្រឹត្តម្តងទៀត (មាត្រា២៧) | ពី ២០.០០០.០០០ ដល់ ១០០.០០០.០០០ | ៣០ថ្ងៃ | |
| II- | **ប្រភេទបទល្មើសចែងក្នុងអនុក្រឹត្យលេខ២៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ២០២១ ស្តីពីការកែសម្រួលមាត្រា៨ នៃអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល** | | | |
| ១០ | អ្នកដំណើរ ឬការីនៃយានដឹកជញ្ជូនដែលគេចវេះមិនឱ្យមន្ត្រីចត្តាឡីស័កធ្វើការត្រួតពិនិត្យ ឬមិនសហការជាមួយនឹងមន្ត្រីចត្តាឡីស័កក្នុងការអនុវត្តវិធានសុខាភិបាល ឬមិនបំពេញតាមបែបបទដែលបានកំណត់ (មាត្រា៨ ថ្មី) | ពី ១.០០០.០០០ ដល់ ៥.០០០.០០០ | ៣០ថ្ងៃ | |
| ១១ | ជនណាដែលផ្តើមគំនិត ដឹកនាំ ណែនាំ ញុះញង់ បញ្ចុះបញ្ចូល ឬជួយសម្រួល ដោយចេតនាដល់អ្នកដំណើរ ឬការីនៃយានដឹកជញ្ជូន ឱ្យគេចចេញពីការត្រួតពិនិត្យ ឬគេចវេះពីការអនុវត្តវិធានការចត្តាឡីស័ក (មាត្រា៨ ថ្មី) | ពី ១០.០០០.០០០ ដល់ ៥០.០០០.០០០ | ៣០ថ្ងៃ | |
| III- | **ប្រភេទបទល្មើសចែងក្នុងច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត** | | | |
| ១២ | អំពើគេចវេះពីការធ្វើចត្តាឡីស័ក ឬកន្លែងធ្វើចត្តាឡីស័កក្នុងអំឡុងពេលធ្វើចត្តាឡីស័ក ករណីបណ្តាលឱ្យឆ្លងដល់អ្នកដទៃ (មាត្រា៧) | | | ពី ២.០០០.០០០ ដល់ ១០.០០០.០០០ |
| ១៣ | អំពើគេចវេះពីការតម្រូវឱ្យទទួលការព្យាបាល ឬគេចចេញពីទីកន្លែងព្យាបាល ឬការប៉ុនប៉ងប្រព្រឹត្តអំពើនេះ (មាត្រា៨) | | | ពី ៥.០០០.០០០ ដល់ ២០.០០០.០០០ |
| ១៤ | អំពើដោយចេតនាមិនគោរពវិធានការរដ្ឋបាល ដែលបានដាក់ចេញស្របតាមច្បាប់នេះ ករណីមិនបណ្តាលឱ្យឆ្លងដល់អ្នកដទៃ(មាត្រា១០) | ពី ១.០០០.០០០ ដល់ ៥.០០០.០០០ | ៣០ថ្ងៃ | |
| ១៥ | អំពើដោយចេតនាមិនគោរពវិធានការរដ្ឋបាល ដែលបានដាក់ចេញស្របតាមច្បាប់នេះ ករណីបណ្តាលឱ្យឆ្លងដល់អ្នកដទៃ (មាត្រា១០) | | | ពី ២.០០០.០០០ ដល់ ១០.០០០.០០០ |
| ១៦ | អំពើដោយចេតនាមិនគោរពវិធានការរដ្ឋបាល ដែលបានដាក់ចេញស្របតាមច្បាប់នេះ ករណីបណ្តាលឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ (មាត្រា១០) | | | ពី ៥.០០០.០០០ ដល់ ២០.០០០.០០០ |
| ១៧ | អំពើរារាំង ឬបង្កឧបសគ្គដោយចេតនាដល់ការអនុវត្តវិធានការដែលបានដាក់ចេញស្របតាមច្បាប់នេះ ករណីមិនបណ្តាលឱ្យឆ្លងដល់អ្នកដទៃ (មាត្រា១១) | | | ពី ២.០០០.០០០ ដល់ ១០.០០០.០០០ |
| ១៨ | អំពើរារាំង ឬបង្កឧបសគ្គដោយចេតនាដល់ការអនុវត្តវិធានការដែលបានដាក់ចេញស្របតាមច្បាប់នេះ ករណីបណ្តាលឱ្យឆ្លងដល់អ្នកដទៃ ឬប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ (មាត្រា១១) | | | ពី ៥.០០០.០០០ ដល់ ២០.០០០.០០០ |



Scanned with CamScanner

**ប្រការ៣ .-**

ក្រសួងសុខាភិបាល មានសមត្ថកិច្ចចេញបង្កាន់ដៃពិន័យអន្តរការណ៍ប្រគល់ជូនទៅបុគ្គល ឬនីតិបុគ្គលដែលបានប្រព្រឹត្តអំពើល្មើសដែលចែងក្នុងប្រការ២ នៃប្រកាសអន្តរក្រសួងនេះ ដោយប្រើប្រាស់ទម្រង់បង្កាន់ដៃពិន័យអន្តរការណ៍ ដែលជាឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ។

ករណីទទួលប្រាក់ពិន័យដោយផ្ទាល់ជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ ក្រសួងសុខាភិបាលត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបោះពុម្ព និងបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រសិនបើបុគ្គល ឬនីតិបុគ្គលដែលប្រព្រឹត្តអំពើល្មើស មិនបានដាក់ពាក្យប្តឹងតវ៉ា ឬមិនបានបង់ប្រាក់ពិន័យអន្តរការណ៍ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលបង្កាន់ដៃពិន័យអន្តរការណ៍ នោះមន្ត្រីសុខាភិបាលដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវកសាងសំណុំរឿងបញ្ជូនទៅសាលាដម្រះក្តីដែលមានសមត្ថកិច្ច ដើម្បីចាត់ការតាមនីតិវិធីជាធរមាន។

**ប្រការ៤ .-**

ក្រសួងសុខាភិបាល ត្រូវរៀបចំគម្រោងចំណូលពីការពិន័យទៅតាមប្រភេទបទល្មើសនីមួយៗ ដែលចែងក្នុងប្រការ២ នៃប្រកាសអន្តរក្រសួងនេះ ដើម្បីដាក់បញ្ចូលទៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

**ប្រការ៥ .-**

ក្រសួងសុខាភិបាល ត្រូវធ្វើរបាយការណ៍ចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។ របាយការណ៍ចំណូលប្រចាំខែ និងប្រចាំឆ្នាំ ត្រូវធ្វើឡើងតាមទម្រង់ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៦ .-**

ការពិន័យដែលចែងក្នុងចំណុចទីII នៃបញ្ជីពិន័យជាប្រាក់ ដែលកំណត់ក្នុងប្រការ២ នៃប្រកាសអន្តរក្រសួងនេះ ត្រូវអនុវត្តជំនួសឱ្យការពិន័យដែលចែងនៅចំណុចទីIII ក្នុងឧបសម្ព័ន្ធ៣ នៃប្រកាសលេខ១៣៥៦ សហវ.ប្រក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងសុខាភិបាល។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។



Scanned with CamScanner

**ប្រការ៧ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម_ប៊ុនហេង**

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ